# តុលាការខេត្តរតនៈគិរី ចោទប្រកាន់លោក ថេង សារឿន និងមន្រ្តី២រូបទៀត ពីបទញុះញង់ និងរួមគំនិតក្បត់

តុលាការខេត្តរតនៈគិរី សម្រេចចោទប្រកាន់លោក ថេង សារឿន និងសហការី២រូបផ្សេងទៀតពីបទញុះញង់ និងរួមគំនិតក្បត់ ក្រោយតំណាងអយ្យការ និងចៅក្រមស៊ើបបានបញ្ចប់នីតិវិធីសាកសួរកាលពីម្សិលមិញ។ ក្រោយការចោទប្រកាន់រួច លោក ថេង សារឿន និងមន្រ្តីរបស់លោក២រូបត្រូវបានតុលាការបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារខេត្តរតនគិរី។ ចំណែកមេធាវីការពារក្តី កំពុងរៀបចំនីតិវិធីច្បាប់ជាបន្តទៀត ដើម្បីអាចសុំសិទ្ធិរស់នៅក្រៅឃុំ។




*លោក ថេង សាវឿន ប្រធានសមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា © CCHR*

បន្ទាប់ពីមន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃសង្ស័យថា ករណីលោក ថេង សាវឿន ជាប់ពាក់ព័ន្ធនឹងផែនការ «បដិវត្តន៍កសិករ»ឥឡូវនេះ តុលាការបានចោទប្រកាន់ ប្រធានសមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជារូបនេះ រួមទាំង លោក ញិុល ភាព ដែលជាមន្ត្រីជាន់ខ្ពស់សមាគម និងលោក ថាច់ ហាច ជាមន្ត្រីសម្របសម្រួលសហគមន៍ នូវបទល្មើសចំនួន២ គឺបទចោទរួមគំនិតក្បត់ តាមមាត្រា៤៥៣ និងបទចោទញុះញង់ តាមមាត្រា៤៩៥។

បទចោទទាំងពីរនេះ តុលាការខេត្តរតនៈគិរី យោងទៅលើការសារភាពរបស់ជនជាប់ចោទ និងភស្តុតាងមួយផ្សេងទៀត គឺខ្លឹមសារលើឯកសារបង្រៀនក្នុងវគ្គបណ្តុះបណ្តាលនាពេលកន្លងមក ដោយមាន

ចេតនាញុះញង់ និងពន្យុះកំហឹងកសិករដែលផ្ទុយពីខ្លឹមសារដើម។ មេធាវីការពារក្តីឱ្យលោក ថេង សារឿន គឺ លោក សំ ទិត្យសីហា ដែលជាមេធាវីរបស់សមាគមអាដហុក សុំមិនឆ្លើយតបដោយលោកអះអាងថា កំពុងធ្វើការជាមួយកូនក្តីនូវដំណើរការច្បាប់បន្តទៀតសិន។

តែយ៉ាងណា លោក ស៊ឹង សែនករុណា អ្នកនាំពាក្យសមាគមអាដហុក ចាត់ទុកបទចោទទាំងពីរនេះធ្ងន់ធ្ងរពេក ពីព្រោះថាវគ្គបណ្តុះបណ្តាលដែលរៀបចំឡើយដោយ សមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជាមិនមានរចនាសម្ព័ន្ធដែលមានចេតនាផ្តួលរលំរដ្ឋាភិបាល ឬពន្យុះកំហឹងកសិករឱ្យកាន់អាវុធដើម្បីប្រឆាំងរដ្ឋាភិបាលឡើយ។ ម្យ៉ាងវិញទៀត លោកថា ក្រុមកសិករ និងលោក ថេង សារឿន មិនមានឥទ្ធិពលឯណាទៅផ្តួលរលំរដ្ឋាភិបាលដែលកំពុងគ្រប់គ្រងអំណាចពេញទីនោះទេ។

សម្រាប់ លោក ស៊ឹង សែនករុណា ករណីលោក ថេង សារឿន និងសហការី២រូបទៀត បើនិយាយការអនុវត្តច្បាប់ឱ្យស្មើភាព និងយុត្តិធម៌ លោកពិបាកថ្លែង ហើយក៏គ្មានជំនឿច្រើនដែរទៅលើប្រព័ន្ធតុលាការកម្ពុជា។ ក៏ប៉ុន្តែជាជំហានបន្ទាប់ទៅមុខ លោកបញ្ជាក់ថា មេធាវីការពារក្តីរបស់សមាគមអាដហុក នឹងធ្វើការតាមផ្លូវច្បាប់បន្តជាមួយតុលាការ ឬអាចប្តឹងជំទាស់ទៅតុលាការកំពូល និងស្នើសុំសិទ្ធិនៅក្រៅឃុំជាដើម។

ដោយឡែក ប្រជាកសិករប្រមាណ២០០នាក់មកពីត្បូងឃ្មុំ ស្វាយរៀង ព្រៃវែង កោះកុង ព្រះសីហនុ និងខេត្តកណ្តាលបានដើរដង្ហែក្បួនដើម្បីដាក់លិខិតទៅកាន់ក្រសួងមហាផ្ទៃសុំកិច្ចអន្តរាគមន៍ដោះលែងប្រធានសមាគម និងមន្ត្រីពីររូបផ្សេងទៀតឱ្យមានសេរីភាពឡើយវិញ។ ក៏ប៉ុន្តែពលរដ្ឋបានបញ្ជាក់ថា ខ្លួនមិនបានទទួលព័ត៌មានច្បាស់ការណ៍ថា ក្រសួងនឹងជួួយអន្តរាគមន៍ពេលណានោះទេ។

គិតមកទល់ពេលនេះ លោក ថេង សាវឿន លោក ញិុល ភាព និង លោក ថាច់ ហាច ត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួន និងឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេល៥ថ្ងៃមកហើយ បន្ទាប់សមត្ថកិច្ចខេត្តក្រចេះស្ទាក់ចាប់ឃាត់ខ្លួនអំឡុងពេលលោក និងក្រុមការងារធ្វើដំណើរតាមរថយន្តមករាជធានីភ្នំពេញវិញកាលពីថ្ងៃទី១៧ ខែឧសភា។

ក្រោយមកនៅយប់ថ្ងៃទី១៨ ខែឧសភា សមត្ថកិច្ចខេត្តក្រចេះបានបញ្ជូនខ្លួនអ្នកទាំងបីមកខេត្តរតនគីរីជាទីដែលពួកលោកបានរៀបចំវគ្គបណ្តុះបណ្តាលជាមួយបុគ្គលិក និងកសិករប្រមាណ៤០នាក់។ ក្រោយមកបញ្ជូនមកដល់ សមត្ថកិច្ចបានចាប់ផ្តើមរៀបចំនីតិវិធីសាកសួរ ខណៈមេធាវីការពារពុំអនុញ្ញាតឱ្យចូលជួបឡើយ ខណៈក្រសួងមហាផ្ទៃចោទប្រកាន់ អ្នកទាំងបីមានគម្រោងធ្វើបដិវត្តន៍កសិករ៕